# សូចនាករតាមដានរួមគ្នាសម្រាប់វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (ថ្ងៃទី១៩- ២០ ខែមិថុនា ឆ្នាំ២០០៧)

## ដើម្បីអនុវត្ត និងត្រួតពិនិត្យតាមកាលបរិច្ឆេទកំណត់រវាងកិច្ចប្រជុំនៃវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ និងលើកទី២

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| **ការអនុវត្តន៍ និងគ្រប់គ្រងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ១- អនុមតិផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ | ១- អនុមតិសេចក្ដីព្រាងបញ្ចប់ផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ ។ នេះគឺជាឯកសារយុទ្ធសាស្ត្រសម្រាប់អនុវត្ត ដោយមានការសម្របសម្រួលពីដៃគូអភិវឌ្ឍន៍ទាំងនេះ ។ | ក្រសួងផែនការ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក.អ.ក/គ.ជ.នា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ផែនការ និងការកាត់បន្ថយភាពក្រីក្រ | នឹងត្រូវកំណត់ពេលក្រោយ | អង្គការសហ-ប្រជាជាតិ<br>ធនាគារពិភពលោក និង<br>ដៃគូអភិវឌ្ឍន៍ |
| | ២- ច្របាច់បញ្ចូលគ្នា នូវរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្ដីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផ្នែក «ការតម្រឹម» នៃរបាយការណ៍ស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការរបស់ ក.អ.ក/គ.ជ.នា ឱ្យទៅជារបាយការណ៍វិភាគតែមួយ ដែលបញ្ជាក់អំពីវឌ្ឍនភាពស្ដីពីការអនុវត្តន៍សូចនាករសំខាន់ៗនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការតម្រឹមធនធានដែលបានសន្យាជាមួយនឹងអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ | ក្រសួងផែនការ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក.អ.ក/គ.ជ.នា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ផែនការ និងការកាត់បន្ថយភាពក្រីក្រ | | |
| ២- អនុវត្ត និងត្រួតពិនិត្យការអនុវត្តន៍បណ្ដាអាទិភាពស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការតាមអភិក្រមភាពជាដៃគូ ដើម្បីសម្រេចតាមគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ១- ពង្រឹងភាពជាម្ចាស់ ការគ្រប់គ្រងដោយផ្អែកលើលទ្ធផល និងគណនេយ្យភាពទ្វេទិស ។ ដៃគូអភិវឌ្ឍន៍ត្រូវ ÷<br>ក- ធ្វើរបាយការណ៍មក ក.អ.ក/គ.ជ.នា នូវព័ត៌មានលំអិតស្ដីពីការគាំទ្រទាំងអស់ (រួមទាំងគំរោងថ្មី និងគំរោងកំពុងអនុវត្ត)<br>ខ- ផ្ដល់ព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពរួច ទៅក្នុងប្រព័ន្ធទិន្នន័យរបស់ ក.អ.ក/គ.ជ.នា និង<br>គ- ចូលរួមពិភាក្សាជាមួយ ក.អ.ក/គ.ជ.នា តាមកាលបរិច្ឆេទកំណត់ ដើម្បីផ្ដល់សុពលភាពលើទិន្នន័យ សម្រាប់តាមដានវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពស្ដីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ។ | ក.អ.ក/គ.ជ.នា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ភាពជាដៃគូ និងសុខដុមនីយកម្ម | មានធនធានគ្រប់គ្រាន់សម្រាប់អនុវត្ត | កម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍន៍ជាច្រើន (MDSP) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ២- អនុវត្ត និងត្រួតពិនិត្យការអនុវត្តន៍បណ្ដាអាទិភាពស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការតាមអភិក្រមភាពជាដៃគូ ដើម្បីសម្រេចតាមគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ២- <u>ជំរុញសុខដុមនីយកម្ម និងការតម្រឹម</u>: ក្រុមការងារបច្ចេកទេសចម្រុះត្រូវរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពស្ដីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងគោលការណ៍ណែនាំស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ច្របាច់បញ្ចូលរបាយការណ៍ទាំងនេះ ឱ្យទៅជាឯកសារតែមួយ សម្រាប់កិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ | កអ. ក/ គ. ជ. នា | ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ | មានធនធានគ្រប់គ្រាន់សម្រាប់អនុវត្ត | កម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍន៍ជាច្រើន (MDSP) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) |
| | ៣- <u>គ្រប់គ្រងដោយផ្អែកលើលទ្ធផល</u>: ពិនិត្យផែនការសកម្មភាពស្ដីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ដោយគ្រោងបន្ថែមសូចនាករមួយចំនួន ។ រៀបចំរបាយការណ៍ស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងវាយតំលៃវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល សម្រាប់បង្ហាញក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។ | ក. អ. ក/ គ. ជ. នា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ភាពជាដៃគូ និងសុខដុមនីយកម្ម | មានធនធានគ្រប់គ្រាន់សម្រាប់អនុវត្ត | កម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍន៍ជាច្រើន (MDSP) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) |
| **អាទិភាពក្នុងវិស័យសង្គមកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ៣- កែលំអកាលានុវត្តភាពសម្រាប់ការសិក្សានៅកំរិតបឋមភូមិ | ១- បង្កើនអត្រាចុះឈ្មោះចូលរៀននៅកំរិតបឋមភូមិ (សរុប និងតាមភេទ) ។<br>២- បង្កើនអត្រាឡើងថ្នាក់ ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ ។ | ក្រសួងអប់រំ យុវជន និងកីឡា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យអប់រំ | | |
| ៤- បង្កើនចំនួនស្ត្រីសម្រាលបុត្រដោយឆ្មបជំនាញ ឱ្យបាន ៤៥% នៅខែធ្នូ ឆ្នាំ២០០៧ (៣៨% ក្នុងឆ្នាំ ២០០៦) | ១- ជ្រើសរើសឆ្មបយ៉ាងតិចចំនួន ៦៨នាក់ ឱ្យបាននៅចុងឆ្នាំ២០០៧ សម្រាប់មណ្ឌលសុខភាពចំនួន៦៨ ដែលបច្ចុប្បន្ននេះ មិនទាន់មានឆ្មប ។ | ក្រសួងសុខាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សុខាភិបាល | | |
| | ២- ផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មប ។ ប្រាក់ឧបត្ថម្ភត្រូវផ្តល់តាមចំនួនសេវា ដែលបានកំណត់ក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល លេខ២៦៨ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧ និងកាំប្រាក់បៀវត្សរ៍របស់ឆ្មប និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់ហានិភ័យក្នុងវិជ្ជាជីវៈ ដែលបានរៀបចំដោយសុខាភិបាល សម្រាប់ស្នើជូនគណៈរដ្ឋមន្ត្រី ពិនិត្យនិងសម្រេច ។ | ក្រសួងសុខាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សុខាភិបាល | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ៥- ពង្រឹងការឆ្លើយតបទៅនឹងការរីករាលដាលនៃជម្ងឺអេដស៍ | ១- ពង្រីកវិសាលភាពនៃការទប់ស្កាត់ ថែរក្សា និងគាំទ្រ ព្រមទាំងវិធានការកាត់បន្ថយផលប៉ះពាល់នៃជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន ។ | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់អេដស៍ | | |
| ៦- សន្តិសុខស្បៀង និងអាហារូបត្ថម្ភនឹងត្រូវឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រតាមវិស័យ | ១- ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ នឹងរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់បញ្ជ្រាបសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សម្រាប់ស្នើជូនក្រសួងពាក់ព័ន្ធពិភាក្សា និងសម្រេច ។ | ក្រសួងផែនការ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | | |
| **អាទិភាពក្នុងវិស័យសេដ្ឋកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ៧- អនុវត្ត និងត្រួតពិនិត្យភាពជាដៃគូក្នុងការអនុវត្តន៍បណ្ដាអាទិភាពនៃវិស័យកសិកម្ម និងទឹក | ១- អនុវត្តជាជំហានៗ នូវយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ÷<br>ក- សម្រេចកិច្ចព្រមព្រៀងស្តីពីគោលការណ៍ សម្រាប់ណែនាំដៃគូអភិវឌ្ឍន៍ និងក្រសួង/ ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលបំពេញការងារក្នុងវិស័យកសិកម្ម និងទឹក នាចុងខែមិថុនា ឆ្នាំ២០០៧<br>ខ- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងដៃគូអភិវឌ្ឍន៍ អនុមតិក្របខ័ណ្ឌយោងសម្រាប់រៀបចំកម្មវិធីជាតិទាំង៥ នៃយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក នាខែកក្កដា ឆ្នាំ២០០៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យកសិកម្ម និងទឹក | | |
| | គ- រៀបចំបញ្ចប់កម្មវិធីជាតិចំនួន២ នាចុងខែធ្នូ ឆ្នាំ២០០៧ និង | | | | |
| | ឃ- រៀបចំបញ្ចប់កម្មវិធីជាតិទាំង៥ នាចុងខែមិថុនា ឆ្នាំ២០០៨ | | | | |
| | ២- កែលំអការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយ ÷<br>ក- ភាគីពាក់ព័ន្ធទទួលបានព័ត៌មានស្តីពីសកម្មភាពទាំងអស់ តាមរយៈការធ្វើបច្ចុប្បន្នភាពព័ត៌មាន២ដងក្នុងមួយឆ្នាំ (ចុងខែមិថុនា និងចុងខែធ្នូ) នៅលើគេហទំព័ររបស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យកសិកម្ម និងទឹក ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យកសិកម្ម និងទឹក | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ ធនធាន | តម្រូវការធនធានដើម្បីសម្រេចគោលដៅ ប្រភព |
|---|---|---|---|---|---|
| ៨- អនុវត្តបទដ្ឋានគតិយុត្តិទាំងឡាយនៃច្បាប់ភូមិបាល | ១- អនុមតិគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និងចាត់វិធានការការពារបឋម (ការបញ្ជាក់ពីអត្តសញ្ញាណដី ការធ្វើផែនទីដីធ្លី ការរៀបចំណាត់ថ្នាក់ដី និងការអនុញ្ញាតិបណ្តោះអាសន្នលើដី ដែលជនជាតិដើមភាគតិចបានទាមទារតាមច្បាប់) ដើម្បីការពារដីរបស់សហគមន៍ជនជាតិដើមភាគតិចទាំងនេះ នៅខេត្តចំនួន២ ក្នុងក្របខ័ណ្ឌរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងក្រុមការងារស្រុក ដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៨ ។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីដីធ្លី | | |
| | ២- លើកកំពស់ការរស់នៅរបស់ប្រជាជនក្រីក្រតាមជនបទ ។ ប្រជាជនចំនួន៥០០គ្រួសារអាចតាំងទីលំនៅលើដីសម្បទានសង្គមកិច្ច ដោយមានការគាំទ្រខាងជីវភាពរស់នៅ និងយ៉ាងតិច មានដីចំនួន១០.០០០ហ.ត ទៀត ត្រូវបានរក្សាទុកសម្រាប់សម្បទានសង្គមកិច្ច ។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ក្រុមការងារបច្ចេកទេសចំរុះសម្រាប់ការងារដីធ្លី | | |
| ៩- ដើម្បីចៀសវាងការបាត់បង់ធនធានព្រៃឈើនៅកម្ពុជា ត្រូវអនុវត្តឱ្យបានពេញលេញ នៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាល នូវក្របខ័ណ្ឌគតិយុត្តិទាំងឡាយ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងព្រៃឈើ ពិសេស ការអនុវត្តន៍អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច | ១- អនុវត្តអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច និងរៀបចំសៀវភៅកត់ត្រាអំពីដីសម្បទានសេដ្ឋកិច្ច សម្រាប់ផ្សព្វផ្សាយជាសាធារណៈ រួមទាំង :<br>- ការសម្រេចរបស់ខេត្តក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច<br>- ពិនិត្យឡើងវិញការផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលមានទំហំច្រើនជាង ១០.០០០ហត ចំនួនយ៉ាងតិច ៥កន្លែង<br>- ចាត់វិធានការសមស្រប ដោយអនុលោមតាមជំពូកទី៦ នៃអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារដីធ្លី និងក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារព្រៃឈើ និងបរិស្ថាន | | |
| | ២- អនុវត្តឱ្យបានឆាប់ និងទំលំទូលាយទូទាំងប្រទេស នូវការកំណត់ព្រំដែនដីព្រៃឈើ ស្របតាមអនុក្រឹត្យលេខ៥៣ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារដីធ្លី និងក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារព្រៃឈើ និងបរិស្ថាន | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ១០- ចាត់វិធានការសមស្រប ដើម្បីឆ្លុះបញ្ចាំងពីអាទិភាពនៃវិស័យជលផលសម្រាប់លើកកំពស់ការជីវភាពរស់នៅរបស់សហគមន៍ជនបទ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ស្រុក ខេត្ត ដោយបញ្ជាក់អំពីការនៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ | ១- ពង្រាងបញ្ចប់នូវក្រមប្រតិបត្តិសម្រាប់ការងារជលផល នាចុងឆ្នាំ ២០០៧ ។ | ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារជលផល | | |
| | ២- ពិភាក្សាជាមួយនឹងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឱ្យរដ្ឋបាលជលផលមានហិរញ្ញប្បទានគ្រប់គ្រាន់ (គិតទាំងចំណូលដែលបានមកពីវិស័យនេះ) សម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន ស្របតាមមាត្រាទី១៤ នៃច្បាប់ជលផល ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារជលផល | | |
| | ៣- ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធផែនការ គណនេយ្យ និងត្រួតពិនិត្យរបស់រដ្ឋបាលជលផល ស្របតាមក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមប្រសិទ្ធភាពការងារ នាចុងឆ្នាំ២០០៧ ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការងារជលផល | | |
| ១១- បន្តកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងគ្រាប់មិនទាន់ផ្ទុះចំនួន ៧០-៨០ និងកាត់បន្ថយឱ្យបាន ៥-១០% នៃដីដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះ | ១- អនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃអំពីការអនុវត្តន៍សកម្មភាពនានាដែលបានចែងក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីមីន និងគ្រាប់មិនទាន់ផ្ទុះ ។ | អាជ្ញាធរសកម្មភាពកំចាត់មីនកម្ពុជា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សកម្មភាពកំចាត់មីន | | |
| | ២- ធានាការផ្តល់ និងការប្រើប្រាស់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ឱ្យបានទាន់ពេលវេលា ។ | អាជ្ញាធរសកម្មភាពកំចាត់មីនកម្ពុជា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សកម្មភាពកំចាត់មីន | | |
| | ៣- កែលំអយន្តការសម្រាប់ត្រួតពិនិត្យការប្រើប្រាស់ធនធាន ឱ្យមានតម្លាភាព និងប្រសិទ្ធភាព ។ | អាជ្ញាធរសកម្មភាពកំចាត់មីនកម្ពុជា | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់សកម្មភាពកំចាត់មីន | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ១២- បង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន | ១- ស្ថាប័នពាក់ព័ន្ធ (ដូចជា ក្រសួងពាណិជ្ជកម្ម សុខាភិបាល កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឧស្សាហកម្ម រ៉ែ និងថាមពល សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ចុះហត្ថលេខា និងអនុវត្តកិច្ចព្រមព្រៀងស្តីពីសេវាកម្ម ដោយភ្ជាប់ជាមួយ នូវបញ្ជីទំនិញហាមឃាត់ដែលបានព្រមព្រៀងរវាងស្ថាប័នទាំងនេះ ។ | ក្រសួងពាណិជ្ជកម្ម សុខាភិបាល កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឧស្សាហកម្ម រ៉ែ និងថាមពល សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រុមការងារស្តីពីវិស័យឯកជន | | |
| | ២- ពិនិត្យការអនុវត្តន៍ការគ្រប់គ្រងហានីភ័យ និងកាត់បន្ថយអត្រាត្រួតពិនិត្យ ឱ្យមកត្រឹម៥០% រួមទាំងតំបន់សេដ្ឋកិច្ចពិសេស ។ ការពិនិត្យនេះនឹងអនុវត្តដោយអនុគណៈកម្មការស្តីពីការអភិវឌ្ឍន៍ពាណិជ្ជកម្ម ។ | ក្រសួងពាណិជ្ជកម្ម | ក្រុមការងារស្តីពីវិស័យឯកជន | | |
| | ៣- លើកអនុសាសន៍ជាក់ស្តែងលើអជ្ញាប័ណ្ណអាទិភាពទាំង២០ ដើម្បីធានាភាពសមស្រប និងប្រសិទ្ធភាព ។ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ក្រុមការងារស្តីពីវិស័យឯកជន | | |
| **អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** | | | | | |
| ១៣- ចីរភាពនៃបណ្តាញផ្លូវជាតិ និងផ្លូវជនបទ | ១- រៀបចំផែនការសកម្មភាពសម្រាប់បង្កើតប្រព័ន្ធគ្រប់គ្រងការថែទាំបណ្តាញផ្លូវ នាខែមិថុនា ឆ្នាំ ២០០៨ ។ | ក្រសួងសាធារណៈការ និងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ | | |
| | ២- ការពារផ្លូវថ្នល់ ដោយ÷<br>ក- អនុវត្តសាកល្បង និងត្រួតពិនិត្យឡើងវិញនូវកិច្ចសន្យាថែទាំផ្លូវថ្នល់តាមរដូវកាល ចំនួន ៣ (ខែមិថុនា ឆ្នាំ ២០០៨) និង<br>ខ- កែលំអ និងរៀបចំកម្មវិធីត្រួតពិនិត្យការផ្ទុកហួសចំណុះ (ខែមិថុនា ឆ្នាំ ២០០៨) | ក្រសួងសាធារណៈការ និងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រុមការងារបច្ចេកចម្រុះ សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ | | |
| ១៤- បង្កើនការប្រើប្រាស់អនាម័យ និងទឹកស្អាត ពិសេសនៅតំបន់ជនបទ | ១- រៀបចំ និងអនុវត្តយុទ្ធសាស្រ្តស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទ និងអនាម័យ ព្រមទាំងថវិកា ដែលផ្អែកលើគោលនយោបាយស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទ និងអនាម័យ ដោយត្រូវតម្រឹមជាមួយនឹងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ។ | ក្រសួងអភិវឌ្ឍន៍ជនបទ | បង្កើតអនុក្រុមការងារ ចំណុះក្រោមក្រុមការងារសមស្រប ណាមួយ | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| **អាទិភាពក្នុងវិស័យអភិបាលកិច្ច និងពហុវិស័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ១៥- បន្តពង្រឹងរដ្ឋបាលសាធារណៈ ដើម្បីបំរើផលប្រយោជន៍ប្រជាជន និងក្លាយជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ | ១- អនុវត្តយុទ្ធសាស្ត្ររួមរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ស្តីពីការឈប់អនុវត្តជាជំហានៗ នូវការផ្តល់ប្រាក់បៀវត្សបន្ថែម ដោយ ÷<br>ក- អនុវត្តផែនការសកម្មភាពតាមវិស័យដែលបានឯកភាព និង<br>ខ- បង្កើតកន្សោមអាទិភាព និងអនុវត្តប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមប្រសិទ្ធភាពការងារ នៅក្រសួងសុខាភិបាល និងយ៉ាងតិចបំផុតនៅក្រសួង/ ស្ថាប័នមួយទៀត | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង ក្រសួងពាក់ព័ន្ធ | ក្រុមការងារស្តីពីកំណែទំរង់រដ្ឋបាល និង ក្រសួងពាក់ព័ន្ធ | | |
| | ២- កែលំអការផ្តល់ប្រាក់បៀវត្សរ៍ និងលក្ខខ័ណ្ឌការងាររបស់មន្ត្រីរាជការ ÷<br>ក- រៀបចំយុទ្ធសាស្ត្រ និងផែនការរយៈពេលមធ្យមសម្រាប់កែលំអបៀវត្សរ៍<br>ខ- រៀបចំគោលនយោបាយ និងផែនការសកម្មភាពស្តីពីការពង្រាយមន្ត្រីរាជការ | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | ក្រុមការងារកំណែទំរង់រដ្ឋបាល | | |
| | ៣- រៀបចំ និងអនុវត្តគោលនយោបាយ និងផែនការសកម្មភាពស្តីពីការគ្រប់គ្រងធនធានមនុស្ស ដោយប្រើប្រាស់មគ្គុទេសក៍ស្តីពីការគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស សម្រាប់មន្ត្រីរាជការស៊ីវិល | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង ក្រសួងពាក់ព័ន្ធ | ក្រុមការងារកំណែទំរង់រដ្ឋបាល និងក្រសួងពាក់ព័ន្ធ | | |
| | ៤- កែលំអការផ្តល់សេវា តាមរយៈការបង្កើតយន្តការបញ្ជរតែមួយ និងពង្រីកក្របខ័ណ្ឌច្បាប់ ដោយបង្កើតបញ្ជរតែមួយ យ៉ាងតិចបំផុត៥កន្លែងទៀតនៅទូទាំងប្រទេស | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | ក្រុមការងារកំណែទំរង់រដ្ឋបាល | | |
| ១៦- រៀបចំប្រព័ន្ធច្បាប់ និងតុលាការឱ្យដំណើរការល្អ ប្រកបដោយគណនេយ្យភាព និងតម្លាភាព ដែលការពារសិទ្ធិបុគ្គល ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ | ១- គោលដៅទី២ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ : បញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ និងអនុមតិច្បាប់សំខាន់ៗដែលនៅសេសសល់ (ក្រមស្តីពីនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទ័ណ្ឌ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់តុលាការ និងច្បាប់ស្តីពីការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម) ។ | ក្រសួងយុត្តិធម៌ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទំរង់ច្បាប់ និងតុលាការ | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមកាងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ១៦- រៀបចំប្រព័ន្ធច្បាប់ និងតុលាការឱ្យដំណើរការល្អ ប្រកបដោយគណនេយ្យភាព និងតម្លាភាព ដែលការពារសិទ្ធិបុគ្គល ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ | ២- គោលដៅទី២ និង៧នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ : រៀបចំបញ្ចប់ នូវគោលការណ៍ណែនាំសម្រាប់ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ដោយផ្អែកលើបទពិសោធន៍កន្លងមក ។ គោលការណ៍ណែនាំនេះនឹងលើកអំពីតម្រូវការខាងកិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់កសាងសមត្ថភាព និងសម្រាប់ពង្រឹងភាពជាម្ចាស់របស់អង្គភាពរៀបចំច្បាប់នៃក្រសួងពាក់ព័ន្ធ ។ | ក្រសួងយុត្តិធម៌ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទំរង់ច្បាប់ និងតុលាការ | | |
| | ៣- គោលដៅទី៤ និង៧ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ : ការបណ្តុះបណ្តាល និងការជ្រើសរើសប្រកបដោយតម្លាភាពនូវមន្ត្រីបំរើឱ្យផ្នែកតុលាការ និងច្បាប់ ដើម្បីកែលំអការផ្តល់សេវាតុលាការ និងកិច្ចដំណើរការរបស់តុលាការ។ | ក្រសួងយុត្តិធម៌ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទំរង់ច្បាប់ និងតុលាការ | | |
| ១៧- ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ | ១- រៀបចំបញ្ចប់ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ស្របតាមបទដ្ឋានជាអន្តរជាតិ ។ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងារកំណែទំរង់ច្បាប់ និងតុលាការ | | |
| | ២- រៀបចំផែនការសម្រាប់គ្រប់គ្រងការអនុវត្តន៍ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ។ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងារកំណែទំរង់ច្បាប់ និងតុលាការ | | |
| | ៣- ផ្សព្វផ្សាយជាទៀងទាត់ ៦ខែម្តងនូវព័ត៌មានស្តីពីករណីអំពើពុករលួយ និងការផ្តន្ទាទោស ។ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងារកំណែទំរង់ច្បាប់ និងតុលាការ | | |
| | ៤- រៀបចំក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ស្តីពីសិទ្ធិទទួលព័ត៌មាន | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងារកំណែទំរង់ច្បាប់ និងតុលាការ | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ១៨- រៀបចំសម្រាប់អនុវត្តឱ្យបានពេញលេញ នូវក្របខ័ណ្ឌយុទ្ធសាស្រ្តជាតិស្តីពីកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ | ១- បន្តរៀបចំសេចក្តីព្រាងច្បាប់អង្គការស្តីពីកិច្ចអភិវឌ្ឍន៍មូលដ្ឋាននៅក្រោមថ្នាក់ជាតិ និងផ្តួចផ្តើមការពិគ្រោះយោបល់ទូលាយ ជាមួយភាគីពាក់ព័ន្ធ (ត្រីមាសទី៤ ឆ្នាំ២០០៧ និងឆ្នាំ២០០៨) ។ | គណៈកម្មាធិការដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ | | |
| | ២- រៀបចំកម្មវិធីជាតិ ដោយបញ្ជាក់ពីទំរង់ការ និងធនធាន សម្រាប់អនុវត្ត (ត្រីមាសទី៣ ឆ្នាំ២០០៧ ដល់ត្រីមាសទី២ ឆ្នាំ២០០៨) ។ | គណៈកម្មាធិការដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ | | |
| | ៣- រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍រៀបចំគោលការណ៍នៃការចូលរួម សម្រាប់គាំទ្រកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ (ត្រីមាសទី៣ និងទី៤ ឆ្នាំ២០០៧) ។ | គណៈកម្មាធិការដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ | | |
| ១៩- បង្កើនជំនឿទុកចិត្តលើថវិការដ្ឋ និងបង្កើនគណនេយ្យភាពក្នុងកិច្ចការហិរញ្ញវត្ថុ | ១- បន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយ ÷<br>ក- រក្សាឱ្យបាននូវសមិទ្ធផលដែលបានសម្រេចកន្លងមក និងអនុវត្តបញ្ចប់នូវបណ្តាសកម្មភាព ដែលនៅសេសសល់ក្នុងដំណាក់កាលទី១<br>ខ- រៀបចំផែនការសកម្មភាពសម្រាប់ជំហានទី២នៃដំណាក់កាលទី២ រួមទាំងផ្តល់អនុសាសន៍សម្រាប់ជាមូលដ្ឋានក្នុងការអនុមតិគំនិតផ្តួចផ្តើមស្តីពីតម្លាភាពក្នុងវិស័យឧស្សាហកម្មរុករក<br>គ- បន្តត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករដែលបានឯកភាពក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ២០- អនុមតិច្បាប់ និងអនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធ ព្រមទាំងអនុវត្តផែនការប្រឆាំងនឹងអំពើហិង្សាគ្រប់ប្រភេទ ព្រមទាំងការជួញដូរស្ត្រី និងកុមារ ស្របតាមបទដ្ឋានអន្តរជាតិ | ១- អនុមតិសេចក្តីព្រាងអនុក្រឹត្យស្តីពីការសំរេចចិត្តផ្នែករដ្ឋបាលស្តីពីអំពើហិង្សាក្នុងគ្រួសារ ។ | ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ និង<br>ក្រសួងការងារ និង<br>បណ្តុះបណ្តាលវិជ្ជាជីវៈ<br>និងក្រសួងកិច្ចការនារី | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់យេនឌ័រ | | |
| | ២- អនុមតិសេចក្តីព្រាងច្បាប់ស្តីពីលុបបំបាត់ការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ ស្របតាមពិធីសារអង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ និងសន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពីឧក្រិដ្ឋកម្មឆ្លងដែន និងសេចក្តីព្រាងក្រមព្រហ្មទ័ណ្ឌ ។ | ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ និង<br>ក្រសួងការងារ និង<br>បណ្តុះបណ្តាលវិជ្ជាជីវៈ<br>និងក្រសួងកិច្ចការនារី | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់យេនឌ័រ | | |
| | ៣- អនុវត្តផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ។ គោលដៅជាក់លាក់សម្រាប់ឆ្នាំ២០០៧នេះ គឺការបង្កើតក្រុមការងារនៅក្រសួងមហាផ្ទៃ សម្រាប់រៀបចំឯកសារបណ្តុះបណ្តាលនានា ដើម្បីអនុវត្តអនុក្រឹត្យនេះ ។ | ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ និង<br>ក្រសួងការងារ និង<br>បណ្តុះបណ្តាលវិជ្ជាជីវៈ<br>និងក្រសួងកិច្ចការនារី | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់យេនឌ័រ | | |
| | ៤- ពិនិត្យឡើងវិញ អំពីគោលនយោបាយ និងបទបញ្ញត្តិស្តីពីអន្តោប្រវេសន៍ ។ គោលដៅជាក់លាក់សម្រាប់ឆ្នាំ២០០៧ រួមមាន÷<br>ក- អនុមតិឯកសារយុទ្ធសាស្ត្រស្តីពីអន្តោប្រវេសន៍ ដោយភ្ជាប់ការងារអន្តោប្រវេសន៍ ជាមួយនឹងការជួញដូរ ការរត់ពន្ធ និងច្បាប់ការងារ ព្រមទាំងកំណែទំរង់ច្បាប់ និង<br>ខ- បំពេញបន្ថែម ការខ្វះចន្លោះខាងទិដ្ឋភាពច្បាប់ ដើម្បីការពារជនអន្តោប្រវេសន៍ ។ | ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ និង<br>ក្រសួងការងារ និង<br>បណ្តុះបណ្តាលវិជ្ជាជីវៈ<br>និងក្រសួងកិច្ចការនារី | ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់យេនឌ័រ | | |